# ដំណើរទស្សនកិច្ចជាផ្លូវការរបស់រដ្ឋមន្ត្រីក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ជប៉ុន




ក្នុងដំណើរអញ្ជើញមកបំពេញទស្សនកិច្ចជាផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា នារសៀលថ្ងៃទី ០២ ខែឧសភា ឆ្នាំ២០០៩កន្លងទៅនេះ គណប្រតិភូកិច្ចការផ្ទៃក្នុង និងគមនាគមន៍ជប៉ុន ដឹកនាំដោយឯកឧត្តម **គុនិអុ ហាតុយ៉ាម៉ា** ( Kunio Hatoyama ) ទេសរដ្ឋមន្ត្រីទទួលបន្ទុកវិមជ្ឈការជប៉ុន និងជារដ្ឋមន្ត្រីក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ និងលោកជំទាវ បានអញ្ជើញចូលរួមប្រជុំទ្វេភាគីជាមួយប្រតិភូក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍កម្ពុជា ដឹកនាំដោយឯកឧត្តម **សូរ ឃុន** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

ក្នុងឱកាសនោះឯកឧត្តមរដ្ឋមន្ត្រី **សូរ ឃុន**បានមានប្រសាសន៍លើកឡើងអំពីការបន្តអភិវឌ្ឍន៍គំរោងទូរគមនាគមន៍នៅកម្ពុជាដែលត្រូវពង្រីកបណ្តាញឆ្អឹងខ្នង និងបណ្តាញបែងចែកនៅតាមទីប្រជុំជននានា និងនៅទីជនបទបន្ថែមទៀតដើម្បីធានាសុវត្ថិភាពក្នុងការបំរើសេវាឱ្យបានល្អ។




ឯកឧត្តមរដ្ឋមន្ត្រីបានបញ្ជាក់ទៀតថា កន្លងមកសហគ្រាសសាធារណៈទូរគមនាគមន៍កម្ពុជា (TC) បានជ្រើសយកក្រុមហ៊ុន K.S.I នៃប្រទេសជប៉ុនធ្វើជាទីប្រឹក្សាគំរោងប្រាក់កំចី JICA ដើម្បីធ្វើការជ្រើសរើស ក្រុមហ៊ុនអនុវត្តគំរោងចំនួន៣សំរាប់ត្រៀមចូលរួមដេញថ្លៃផ្គត់ផ្គង់គំរោង និងបន្តជំរុញការអនុវត្តន៍គំរោងបណ្តាញទូរគមនាគមន៍អនុតំបន់មេគង្គក្រោមឥណទាន JICA ។

ឯកឧត្តមរដ្ឋមន្ត្រី**សូរ  ឃុន** បានបញ្ជាក់ជូនភាគីជប៉ុនថា សេចក្តីព្រៀងច្បាប់ស្តីអំពីទូរគមនាគមន៍ត្រូវបាន គណៈរដ្ឋមន្ត្រីសំរេចឯកភាពក្នុងអាណត្តិទី៣កាលពីថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០០៦ហើយបានផ្ញើជូនរដ្ឋសភារួចហើយ នៅពេលនោះ ប៉ុន្តែសេចក្តីព្រៀងច្បាប់នេះត្រូវបានរដ្ឋសភាបង្វែរមកគណៈរដ្ឋមន្ត្រីវិញនៅក្នុងអាណត្តិទី៤នេះ ដើម្បី ធ្វើការកែសំរួលហើយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ក៏បានធ្វើការកែសំរួល ហើយដាក់ជូនគណៈរដ្ឋមន្ត្រី ពិនិត្យ និងសំរេច ដើម្បីផ្ញើជូនរដ្ឋសភាអនុម័តជាថ្មី។



លើសពីនោះឯកឧត្តមរដ្ឋមន្ត្រី **សូរ  ឃុន** បានបន្តទៀតថា ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ កំពុង សិក្សាអំពីបច្ចេកវិទ្យាទូរគមនាគមន៍ទំនើបផ្សេងៗទៀត ដើម្បីឈានទៅរៀបចំគំរោងមេនៃការអភិវឌ្ឍន៍បណ្តាញ IP ទូទាំងប្រទេសកម្ពុជា។ ដូចនេះក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍កម្ពុជា ចង់ឱ្យក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ជប៉ុនពិនិត្យមើលលទ្ធភាព ដើម្បីជួយរៀបចំសិក្សា និងបន្តជួយអភិវឌ្ឍនូវគំរោងខាងលើ។ ទោះបី មានការរីកចំរើនលើវិស័យទូរគមនាគមន៍ ក៏សហគ្រាសសាធារណៈទូរគមនាគមន៍កម្ពុជានៅមានកំរិតលើការពង្រឹង សមត្ថភាពរបស់ខ្លួនទាំងបច្ចេកទេស និងបទពិសោធន៍ផ្សេងៗសំរាប់ការអភិវឌ្ឍន៍វិស័យទូរគមនាគមន៍។ ជាមួយគ្នា នោះដែរ ឯកឧត្តមរដ្ឋមន្ត្រីក៏បានស្នើសុំឱ្យក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ជប៉ុនជួយបណ្តុះបណ្តាលមន្ត្រី និង នយោជិតជំនាញរបស់សហគ្រាសសាធារណៈទូរគមនាគមន៍កម្ពុជា។

ឯកឧត្តម **សូរ  ឃុន** បានបន្ថែមថា នៅព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ននេះមានក្រុមហ៊ុនជាច្រើនបាន ប្រកបអាជីវកម្មលើវិស័យទូរគមនាគមន៍ ហើយបាន និងកំពុងប្រកួតប្រជែងលើទីផ្សារសេរី។

ឆ្លើយតបទៅនឹងសំណើររបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍កម្ពុជាឯកឧត្តមទេសរដ្ឋមន្ត្រី **គុនិអុ ហារ៉ាតុយ៉ាម៉ា** បានសំដែងនូវការគាំទ្រ និងត្រៀមលក្ខណៈជួយបណ្តុះបណ្តាលមន្ត្រីទូរគមនាគមន៍កម្ពុជា ហើយតាម រយៈកិច្ចប្រជុំទ្វេភាគីរវាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍កម្ពុជា និងក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ ក្នុងថ្ងៃនេះនឹងផ្តល់ផលប្រយោជន៍យ៉ាងច្រើនដល់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍កម្ពុជាលើការងារទំនាក់

ទំនងក្នុងវិស័យទូរគមនាគមន៍ទាំងស្ថាប័នរដ្ឋ និងឯកជន ជាពិសេសគឺសំរាប់ជាមូលដ្ឋានដើម្បីបង្កើនគុណភាពសេវាទូរគមនាគមន៍ ។

ឯកឧត្តមទេសរដ្ឋមន្ត្រីជប៉ុនក៏បានកោតសរសើរផងដែរអំពីកំណើនសេដ្ឋកិច្ចយ៉ាងខ្លាំងនៅក្នុងប្រទេសកម្ពុជាក្នុងបណ្តាឆ្នាំថ្មីៗនេះដោយការខិតខំកសាងប្រទេសជាតិ និងការរស់ឡើងវិញនៃវិស័យសេដ្ឋកិច្ចនេះក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ហើយឯកឧត្តមបានបញ្ជាក់ទៀតថា ដោយឡែកកំណើនសេដ្ឋកិច្ចនៅក្នុងប្រទេសជប៉ុនស្រូបយកពីវិស័យទូរគមនាគមន៍ប្រមាណ៤០% នៃចំណូលទាំងមូលរបស់ប្រទេស ។

ឯកឧត្តមទេសរដ្ឋមន្ត្រីបានជ្រាបច្បាស់ពីផលលំបាករបស់ប្រទេសកម្ពុជា ប៉ុន្តែទោះបីជាយ៉ាងណាក៏ឯកឧត្តម **សូរ ឃុន** បានពុះពារជំនះធ្វើឱ្យវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍កម្ពុជាមានការអភិវឌ្ឍន៍យ៉ាងខ្លាំងក្លា ដើម្បីបំរើសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់ ។



ឯកឧត្តម **គុនិអុ ហាតុយ៉ាម៉ា**បានបន្តទៀតថា ឯកឧត្តមក៏ធ្លាប់ធ្វើជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជប៉ុនហើយ ធ្លាប់ជួយដល់កម្ពុជាលើការបណ្តុះបណ្តាលធនធានមនុស្សលើវិស័យយុត្តិធម៌ទៀតផង ។ ជាងនេះទៅទៀតឯកឧត្តមទេសរដ្ឋមន្ត្រីក៏បានសុំធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍លើវិស័យទូរគមនាគមន៍ ។

បន្ទាប់មកភាគីទាំងពីរ គឺក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍កម្ពុជាដឹកនាំដោយឯកឧត្តម រដ្ឋមន្ត្រី **សូរ ឃុន** និងក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ជប៉ុនដឹកនាំដោយ ឯកឧត្តមទេសរដ្ឋមន្ត្រី **គុនិអុ ហាតុយ៉ាម៉ា** បានចុះហត្ថលេខាលើកំណត់ហេតុនៃកិច្ចប្រជុំពិភាក្សាស្តីអំពីកិច្ចសហប្រតិបត្តិការ រវាងក្រសួងខាងលើនៃប្រទេសទាំងពីរនេះ ។